


# «អប្សរា» ពីទេវកថា ឥណ្ឌា មកចម្លាក់ខ្មែរ និង របាំតន្តីខ្មែរ

# "APSARA" FROM INDIAN MYTHOLOGY TO KHMER SCULPTURE AND KHMER CLASSICAL DANCE

*ដោយ*

បណ្ឌិតសភាចារ្យ **សោម សុមុនី**

*សមាជិកពេញសិទ្ធិ*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

*២០១៨*

# សន្និសីទអន្តរជាតិ
# ស្តីពី
# «តម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិកៈ វប្បធម៌, ប្រវត្តិ និងមោទនភាព»

*ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨, ក្រុងសៀមរាប, ខេត្តសៀមរាប*

## "អប្សរា» ពីទេវកថាឥណ្ឌា មកចម្លាក់ខ្មែរ និងរបាំគន្លឹះខ្មែរ

"APSARA" FROM INDIAN MYTHOLOGY

TO KHMER SCULPTURE AND KHMER CLASSICAL DANCE

ដោយបណ្ឌិតសភាចារ្យ **សោម សុមុនី**

*សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

ប្រជាជនកម្ពុជា ជាប្រជាជនដែលធ្លាប់មានអរិយធម៌រុងរឿង តាំងពីយូរលង់ណាស់មកហើយ។ បច្ចុប្បន្ន ទោះបីមាតុភូមិធ្លាប់បានខ្ទេចខ្ទាំដោយសារសង្គ្រាមជាច្រើនទសវត្សរ៍កន្លងមក ក៏ប្រជាជនខ្មែរនៅតែមានអ្វីៗដែលអាចជាគ្រឿងសម្រាប់លើកទឹកចិត្តឱ្យមានសុទិដ្ឋិនិយមក្នុងការស្តារ និងកសាងប្រទេសឆ្ពោះទៅរកការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ប្រការមួយដែលប្រជាជនខ្មែរនៅតែមានមោទនភាពនោះ គឺដោយមានមរតកវប្បធម៌ដែលបុព្វបុរសយើងបានបន្សល់ទុកមកជាច្រើនឥតគណនា ក្នុងនោះយើងមានរតនសម្បត្តិអង្គរដែលពិភពលោកទាំងមូលកោតស្ញប់ស្ញែង ជាមរតកខាងសិល្បៈស្ថាបត្យកម្មនិងសំណង់។ ផ្នែកនាដកម្ម យើងមានល្ខោនអាយ៉ៃ យីកេ ចំណែកខាងសិល្បៈតូរ្យតន្ត្រី យើងមានបទភ្លេងមហោរី ប្រពៃណី ប្រជាប្រិយ និងបទភ្លេងទំនើបចម្រុះដែលសុទ្ធសឹងជាមរតកដ៏មានតម្លៃរបស់ជាតិ។ រីឯមរតកខាងសិល្បៈរបាំដែលជាអត្តសញ្ញាណជាតិ យើងមាន «របាំអប្សរា» ដែលជារបាំមួយស្ថិតក្នុងចំណោមរបាំព្រះរាជទ្រព្យដ៏មានឈ្មោះល្បីល្បាញ ដែលពិភពលោកទទួលស្គាល់និងវាយតម្លៃថាជារបាំគន្លឹះខ្មែរ (Khmer Classical Dance)។

របាំអប្សរា រួមទាំងរបាំព្រះរាជទ្រព្យទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកវប្បធម៌អរូបីនៃមនុស្សជាតិ ដោយអង្គការយូណេស្កូ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៣។ ការចារឹកនាម នៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញនេះបានបញ្ជាក់ពីតម្លៃជាសាកលដ៏ធំធេងអស្ចារ្យនៃស្នាដៃសិល្បៈរបាំគន្លឹះ

ប្រកបដោយអត្ថន័យវប្បធម៌នេះ។ ចំពោះប្រជាជនកម្ពុជាទូទៅ របាំអប្សរា គឺជាមោទនភាព ជានិមិត្តរូបជាតិ និងប្រជាជន។ របាំអប្សរា ស្ថិតនៅយ៉ាងជ្រាលជ្រៅក្នុងជម្រៅបេះដូងខ្មែរគ្រប់ៗរូប។

ដោយឃើញនូវតម្លៃសាកលដ៏ធំធេងអស្ចារ្យនៃរបាំអប្សរានេះហើយ ទើបយើងសម្រេចលើកយកអត្ថបទសិក្សាស្ដីអំពី ***«អប្សរា» ពីទេវកថាឥណ្ឌាមកចម្លាក់ខ្មែរ និងរបាំតន្ត្រីខ្មែរ*** មកចូលរួមក្នុងសន្និសីទអន្តរជាតិលើកទី១៤ ស្ដីអំពី «**តម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិក៖ វប្បធម៌ ប្រពៃណី និងមោទនភាព**»។

អត្ថបទស្ដីអំពី ***«អប្សរា» ពីទេវកថាឥណ្ឌាមកចម្លាក់ខ្មែរ និងរបាំតន្ត្រីខ្មែរ*** នេះនឹងលើកឡើងអំពីប្រភពកំណើតនៃរបាំអប្សរាខ្មែរដែលមានជាអាទិ៍ គឺទេវកថាឥណ្ឌា «រឿងអណ្ដើកកូម៌ៈ» (ឬរឿងកូរសមុទ្រទឹកដោះ) និងសិល្បៈវិចិត្រកម្មជារូបចម្លាក់ទេពអប្សរ ឬអប្សរា សំដែងកាយវិការយ៉ាងស័ក្ដិសមរាប់រយនៅតាមប្រាសាទដ៏ស្កឹមស្កៃទាំងឡាយក្នុងតំបន់អង្គរ ព្រមទាំងប្រវត្តិនៃការបង្កើតរបាំ។ អត្ថបទនេះមិនមានលម្អិតអំពីអត្ថន័យសិល្បៈក្នុងរបាំនោះទេ។

## ១. បញ្ញត្តិ «អប្សរា»

ក្នុងការសិក្សា យើងរកឃើញទស្សនៈនានាស្ដីអំពី «អប្សរា»។

តាមវចនានុក្រមខ្មែរ រៀបរៀងដោយសម្ដេចព្រះសង្ឃរាជ ***ជួន ណាត*** ដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ «អប្សរា» ដូចគ្នានឹង «អច្ឆរា» «ស្រីអប្សរា»។ ពាក្យដើមគឺ «អប្សរ» (មកពីពាក្យសំស្ក្រឹត *អប្សរស៑* ឬ *អប្សរា* ឯពាក្យបាលីថា *អច្ឆរា* ដែលមានន័យថា៖ «ស្រីមានសម្បុរថ្លាស្រស់ផូរផង់ ឬស្រីមានមុខថ្លាស្រស់បំព្រង»)។ ក្នុងការនិយមរបស់ខ្មែរ «អប្សរា» គឺ ស្រីសួគ៌ ស្រីអប្សរ ស្រីទេពអប្សរ នាងអប្សរ។ សម្ដេចជួន ណាត បានលើកឡើងថា «តាមសេចក្ដីតំណាលក្នុងគម្ពីរព្រាហ្មណ៍ថា ស្ត្រីសួគ៌ពួកមួយដែលផុសឡើងអំពីទឹក ក្នុងកាលដែលកូរទឹកអម្ឫត»ក៏ប៉ុន្តែ លោកបានបដិសេធសេចក្ដីបកស្រាយនេះ[១]។

តាម Cambodian-English Dictionary បោះពុម្ពផ្សាយដោយ The Catholic University of America Press, Washington, D.C. 20064, 1977 «អប្សរា» គឺជាស្រីសួគ៌ ស្រីទេពអប្សរ (មកពីពាក្យសំស្ក្រឹត apsaras, apsarä) ត្រូវនឹងពាក្យអង់គ្លេសថា celestial nymph មានន័យថាជាទេពធីតាឋានផ្សេង (ពាក្យ nymph ក្នុងអក្សរសិល្ប៍បុរាណក្រិកគឺជាទេវៈដែលមានរូបរាងជានារីវ័យក្មេង), angel ជាទេវតា, divine female ជាទេពធីតា, celestial dancer ជាអ្នករបាំឋានសួគ៌[២]។

ក្នុងការបកស្រាយពាក្យ APSARA ក្នុង Le Petit Robert Dictionnaire De La Langue Française របស់លោក Paul Robert បញ្ជាក់ថាគេបានស្គាល់ Apsara ដែលជាចម្លាក់នៅប្រាសាទអង្គររបស់ខ្មែរ ៖ "APSARA (apsara] n. f. — 1823; mot hindi • Déesse inferieure, dans la mythologie indienne; sa représentation dans l'art. Les apsaras du temple d'Angkor-Vat." (*បកប្រែ៖ APSARA ជាពាក្យក្នុងភាសា*

---

[១] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ទំព័រ១៦៥៣

[២] Cambodian-English Dictionary បោះពុម្ពផ្សាយដោយ The Catholic University of America Press, Washington, D.C. 20064, 1977 ទំព័រ១៣៦៩

*hindi; ភាសាផ្លូវការមួយប្រើនៅប្រទេសឥណ្ឌាភាគខាងជើង; APSARA ជាទេពធីតាសាមញ្ញ, ក្នុងទេវកថាឥណ្ឌា, មានការបង្ហាញខ្លួនតាមសិល្បៈ។ អប្សរាទាំងឡាយនៅប្រាសាទអង្គរវត្ត។*) ។

តាមការបកស្រាយខាងលើ ឃើញថា ជាឫសគល់ «អប្សរា» គឺស្ថិតក្នុងវប្បធម៌ឥណ្ឌាគឺទេវកថាឥណ្ឌា រឿង «អណ្ដើកកូម៌ៈ» ឬរឿង«កូរសមុទ្រទឹកដោះ» ទោះបីសម្ដេចព្រះសង្ឃរាជ *ជួន ណាត* លោកមិនទទួលយកក៏ដោយ ហើយយើងក៏មិនអាចគិតថាហេតុអ្វីបានជាសម្ដេចព្រះសង្ឃរាជ លោកបដិសេធការលើកឡើងថា«តាមសេចក្ដីតំណាលក្នុងគម្ពីរព្រាហ្មណ៍ថា ស្រ្តីសួគ៌ពួកមួយដែលផុសឡើងអំពីទឹក ក្នុងកាលដែលកូរទឹកអម្រឹត»នោះទេ (កូរទឹកអម្រឹត ជាសេចក្ដីនៃរឿង គឺកូរសមុទ្រទឹកដោះដើម្បីយកទឹកអម្រឹតដែលធ្វើឱ្យជីវិតមានភាពអមតៈ)។

## ២. «**អប្សរា**» **ក្នុងទេវកថាឥណ្ឌា**

«អប្សរា» មានដំណាលក្នុងរឿង *អណ្ដើកកូម៌ៈ* ឬ រឿង *កូរសមុទ្រទឹកដោះ*។

កាលដើមឡើយ មានមហាសមុទ្រទឹកដោះនៅលើចក្រវាលទាំងមូល។ ពួកទេវតា និងអសុរាដែលចង់បានទឹកអម្រឹត គឺទឹកមន្តជីវិតអមតៈ បានច្បាំងគ្នាដើម្បីទឹកអម្រឹត។ ដោយហេតុចម្បាំងអស់ពេលដ៏យូរ ក៏មិនចាញ់មិនឈ្នះ ព្រះវិស្ណុក៏ចេញមកពន្យល់ពួកទេវតា និងអសុរាឱ្យរួមគ្នាកូរសមុទ្រទឹកដោះនោះ។ នៅក្នុងសមុទ្រទឹកដោះ មានទឹកអម្រឹតនិងវត្ថុទិព្វជាច្រើនឥតគណនា ដោយចង់ឃើញនូវវត្ថុទិព្វទាំងនោះ និងចង់បាននូវជីវិតអមតៈ ទាំងពពួកទេវតា និងអសុរាបានយល់ព្រមតាមព្រះវិស្ណុរួមគ្នាកូរសមុទ្រទឹកដោះដោយសន្យាគ្នាថា បើទឹកអម្រឹតលេចឡើងចំមុខពពួកទេវតានោះទឹកអម្រឹតបានទៅពពួកទេវតា បើទឹកអម្រឹតលេចឡើងចំមុខពពួកអសុរានោះទឹកអម្រឹត នឹងបានទៅពពួកអសុរា។ ព្រះវិស្ណុបានដកភ្នំមន្ទរៈយកមកធ្វើជាឧបករណ៍សម្រាប់កូរ ហើយបែងខ្លួនជាអវតារមានឈ្មោះថា «*អណ្ដើកកូម៌ៈ*»ដើម្បីទ្រភ្នំមន្ទរៈកុំឱ្យលិច។ កាលនោះស្ដេចនាគឈ្មោះ ***វាសុកី*** បានយកខ្លួនធ្វើជាព្រ័ត្រសម្រាប់ឱ្យគេទាញ។ ពួកទេវតាទាញខាងកន្ទុយ ឯពួកអសុរាទាញខាងក្បាល។

ការកូរសមុទ្រទឹកដោះប្រព្រឹត្តទៅអស់រយៈពេលជាងមួយពាន់ឆ្នាំនៅស្ថានទេវលោក។

វត្ថុទិព្វដែលផុសចេញពីការកូរសមុទ្រទឹកដោះរួមមាន ៖

១. *ផ្កាបណ្ណជាតិ* ថ្វាយទៅព្រះព្រហ្មយកទៅដាំនៅព្រហ្មលោកទាំងដប់ប្រាំមួយជាន់

២. *ដំរីក្បាលបី* ឈ្មោះ *ឰរាវ័ណ* ថ្វាយទៅព្រះឥន្ទ្រធ្វើជាយានជំនិះ

៣. *ព្រះនាងស្រីលក្ស្មី* ថ្វាយទៅព្រះវិស្ណុធ្វើជាអគ្គមហេសី

៤. *សេះស* ឈ្មោះ *ឧច្ចៃស្រវៈ* ទេពនិម្មិតនេះមិនថ្វាយឱ្យអាទិទេពអង្គណាទេ តែរក្សាទុកជានិមិត្តរូបគោរពប្រតិបត្តិសីលប្រាំសម្រាប់ឋានទាំងបី គឺឋានទេវលោក ឋានមនុស្សលោក និងឋានបាតាល។

៥. *ទឹកអម្រឹត* ជាវត្ថុស័ក្តិសិទ្ធិធ្វើឱ្យមានអាយុវែងឥតដែនកំណត់។

៦. *អប្សរា* ទេពអប្សររាប់សិបអង្គលេចចេញឡើងអណ្ដែតពាសពេញលំហអាកាស រាំរបាំសួគ៌ បន្ទាប់ពីវត្ថុសក្តិសិទ្ធិទីប្រាំ គឺទឹកអម្រឹតបានធ្លាក់ទៅក្នុងដៃពួកអសុរា។ ប្រមុខអប្សរធ្វើសញ្ញាឱ្យបរិវាររាំរបាំទេពពង្វក់ចិត្តពួកអសុរាឱ្យភ្លឹកភ្លេចផឹកទឹកអម្រឹត។ របាំទាក់ទាញពួកអសុរាឱ្យស្រើបស្រាលស្លុតស្លុងអារម្មណ៍ទៅតាមក្បាច់រាំ។ ឃើញឱកាសល្អ ព្រះវិស្ណុក៏កាឡាខ្លួនជាព្រះពាយឆក់យកទឹកអម្រឹតឱ្យពួកទេវតាក្រេបទាំងអស់ដើម្បីឱ្យមានជីវិតអមតៈ។

ពេលបេសកកម្មកូរសមុទ្រទឹកដោះបានចប់សព្វគ្រប់ហើយពួកស្រីទេពអប្សរទាំងអស់បានក្លាយទៅជាស្រីរបាំសួគ៌រាំថ្វាយព្រះឥន្ទ្រតាំងតែពីកាលនោះមក។

របាំរបស់ពពួកស្រីទេពអប្សរនោះសន្មត់ហៅថា«*របាំអប្សរា*»។ របាំអប្សរារាំលើកទីមួយនៅឋានសមុទ្រទឹកដោះហៅថា របាំទឹកអម្ឫត។ ពេលរេរាំពពួកទេពអប្សរតែងកាន់ផ្កាបណ្ណជាតិជានិច្ចដែលតំណាងឱ្យទេវលោក សុភមង្គល និងភាពរុងរឿងរបស់សត្តនិករគ្រប់ឋាន។

## ៣. «អប្សរា» ក្នុងសិល្បៈចម្លាក់ខ្មែរ

ទាក់ទងនឹងស្ថាបត្យកម្មសំណង់ដែលជាអត្តសញ្ញាណវប្បធម៌ជាតិ ប្រទេសអេហ្ស៊ីបមានប្រាសាទពីរ៉ាមីត ប្រជាជាតិចិនមានមហាកំពែង ប្រជាជាតិខ្មែរមានប្រាសាទបុរាណរយពាន់ ជាពិសេសប្រាសាទអង្គរវត្តដ៏ល្បីល្បាញទូទាំងសកលលោក។ ជាទូទៅការអធិប្បាយក្នុងបរិបទស្ថាបត្យកម្ម ឬ សំណង់ គេប្រើត្រឹមពាក្យថា «ស្ថាបត្យកម្ម» ដោយឡែកក្នុងស្ថាបត្យកម្មសំណង់ប្រាសាទបុរាណខ្មែរ កាលណាគេនិយាយអំពីស្ថាបត្យកម្ម គឺគេនិយាយដោយភ្ជាប់ជាមួយពាក្យ «សិល្បៈ» គឺ«សិល្បៈស្ថាបត្យកម្ម»។ ការដែលប្រើពាក្យ «សិល្បៈ» ភ្ជាប់ជាមួយ«ស្ថាបត្យកម្ម» ក្នុងសំណង់ប្រាសាទបុរាណខ្មែរ ពីព្រោះប្រាសាទទាំងឡាយដែលបុព្វបុរសខ្មែរលោក មិនត្រឹមតែមានភាពស្កឹមស្កៃជាសក្ខីកម្មនៃស្ថាបត្យកម្ម និងវិស្វកម្មដ៏អស្ចារ្យលើលោកប៉ុណ្ណោះទេ តែថែមទាំងមានភាពប្រណីតដោយសិល្បៈវិចិត្រកម្មជាក្បូរក្បាច់រចនារស់រវើក ជាពិសេសគឺមានរូបចម្លាក់រាប់រយជាទេពអប្សរ ឬអប្សរាសំដែងកាយវិការនាដកម្មស័ក្តិសមគ្មានពីរ ដែលជាសមិទ្ធផលនៃបញ្ញាញាណបុព្វបុរសខ្មែរ។

ទេវកថារឿង អណ្តើកកូម៌ៈ របាំអប្សរា និងទេពអប្សរា ក៏មានឆ្លាក់នៅលើផ្តែរ និងលើថែវប្រាសាទមួយចំនួនផងដែរ។



*រូបអប្សរាដែលតាមនិទានថា ជាស្រីសួគ៌មួយក្រុមកើតមានដោយសារការកូរសមុទ្រទឹកដោះដើម្បីស្វែងរកទឹកអម្ឫត។ រូបនាងត្រូវបានបុព្វបុរសខ្មែរឆ្លាក់លើសិលានៃប្រាសាទទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជា។ រូបនេះជាចម្លាក់ទាក់ទងនឹងរឿងអណ្តើកកូម៌ៈ ឆ្លាក់នៅថែវខាងកើតនៃប្រាសាទអង្គរវត្ត។*



រូបនេះជាចម្លាក់ទាក់ទងនឹងរឿងសមណ្ឌិកកូទៈ ឆ្លាក់នៅប្រាសាទព្រះវិហារ



ចម្លាក់អប្សរានៅប្រាសាទបាយ័ន



ចម្លាក់របាំអប្សរានៅប្រាសាទបាយ័ន



ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត

## ៤. «អប្សរា»ក្នុងសិល្បៈរបាំខ្មែរ ៖ «របាំអប្សរា»

របាំអប្សរាត្រូវបានបង្កើតឡើងតាមព្រះរាជតម្រិះរបស់ព្រះនាយិកាសាលាសុធារសក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៥០ ព្រះនាម *សម្តេចព្រះរាជកនិដ្ឋា នរោត្តម ស្មើសោភ័ណ* ជាព្រះអនុជនៃព្រះបាទ *នរោត្តម សុរាម្រឹត*។ ព្រះនាយិកាមានគំនិតបង្កើតរបាំនេះឡើង គឺដើម្បីប្រគល់រង្វាន់លើកទឹកចិត្តដល់អ្នកចូលរួមសម្តែងជាសិស្សពូកែក្នុងកម្មវិធីដែលតែងតែប្រព្រឹត្តទៅនៅរាល់ដំណាច់ឆ្នាំសិក្សា។ ព្រះអង្គបានបង្ហាត់របាំនេះដំបូងក្នុងអំឡុងឆ្នាំ១៩៥៨ ដោយមាន *ព្រះអង្គម្ចាស់ក្សត្រី នរោត្តមវិជ្ជា* ព្រះរាជបុត្រីព្រះបាទ *នរោត្តម សុរាម្រឹត* រាំជាតួឯក។

ឆ្នាំបន្ទាប់សម្តែងដោយ *ព្រះអង្គម្ចាស់ក្សត្រី នរោត្តមសុជាតិវត្តីយា* ព្រះរាជបុត្រី *ព្រះបាទនរោត្តម សីហនុ* និងជាសិស្សអ្នកគ្រូ *ជា សាមី* ជាគ្រូរបាំនៅព្រះបរមរាជវាំង និងនៅសាលាសុធរស ក្នុងសម័យនោះ[៣]។



***ព្រះអង្គម្ចាស់ក្សត្រី នរោត្តមវិជ្ជា ព្រះរាជបុត្រីព្រះបាទនរោត្តម សុរាម្រឹត រាំជាតួឯក***

នាដការីឯកនៃរបាំអប្សរាដែលបង្កើតកិត្យានុភាពរបាំនេះលើឆាកអន្តរជាតិគឺ *ព្រះអង្គម្ចាស់ក្សត្រី នរោត្តម បុប្ផាទេវី* ព្រះរាជបុត្រីព្រះបរមរតនកោដ្ឋ ព្រះករុណា នរោត្តម សីហនុ។

---

[៣] កែវ ណារុំ និង ព្រំ ស៊ីសាផាន្នា «របាំអប្សរា» ការផ្សាយរបស់គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ ឆ្នាំ២០០៣ ទំព័រ១១-១២



***ម្ចាស់ក្សត្រី នរោត្តម បុប្ផាទេវី***

តាមការបង្ហាញរបស់អ្នកគ្រូ *កែវ ណារុំ* និង *ព្រំ ស៊ីសាផាន្នា* ក្នុងសៀវភៅ «របាំអប្សរា» បោះពុម្ពផ្សាយដោយគណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈនៅឆ្នាំ២០០៣ ឃើញថារូបចម្លាក់

រាប់រយជាទេពអប្សរ អប្សរាសំដែងកាយវិការ នាដកម្មស័ក្តិសមគ្មានពីរនៅអង្គរនោះ គឺជាប្រភពនៃការបង្កើតរបាំអប្សរានេះ[៤]។

ក្នុងរបាំអប្សរាដែលជារបាំតន្ត្រីខ្មែរ ទាំងសម្លៀកបំពាក់ ទាំងគ្រឿងអលង្ការ ទាំងកាយវិការរាំ សុទ្ធសឹងតាមលំនាំចម្លាក់អប្សរា ដែលតាមនិទានថា  ជាស្រីសួគ៌មួយក្រុមកើតមានដោយសារការកូរសមុទ្រទឹកដោះ ដើម្បីរកទឹកអម្ឫត និងដែលរូបនាងត្រូវបានបុព្វបុរសខ្មែរឆ្លាក់លើសិលានៃប្រាសាទទាំងឡាយ ជាពិសេសនៅប្រាសាទអង្គរវត្ត។



*សម្លៀកបំពាក់ គ្រឿងអលង្កា និងកាយវិការរាំក្នុងរបាំអប្សរាដែលយកតាមលំនាំ ចម្លាក់អប្សរា*
*(រូបភាពពីសៀវភៅ "របាំអប្សរា" ដោយអ្នកគ្រូកែវ ណារុំ និង ព្រំ ស៊ីសាផាន្នា ឆ្នាំ២០០៣)*

[៤] កែវ ណារុំ និង ព្រំ ស៊ីសាផាន្នា «របាំអប្សរា» ដ-ឯ-ម ទំព័រ១-២

នាដកម្មនៅសម័យនោះមានលំនាំប្រហាក់ប្រហែលរបាំក្នុងនារី ដោយ *ម៉ម ធាវី* និងបានដកស្រង់ពាក្យខ្លះពីរឿង *អ៊ីណាវបុស្បា*។ ការដាក់ក្បាច់ និង ការរើសភ្លេងមកបំពេញ អ្នកគ្រូ *ជា សាមី* ជាអ្នករៀបចំ។ អ្នកច្រៀងកំដរមានអ្នកគ្រូ *ជា ខាន់* និង អ្នកគ្រូ *ឯម ធាយ* ដែលយកតាមលំនាំបទ *ដើមឈឹង*។

របាំអប្សរាបានឈានទៅដល់កម្រិតល្អឥតខ្ចោះក៏មានការរៀបចំសម្តែងនៅខេត្តសៀមរាបនៅប្រាសាទអង្គរដើម្បីថតជាខ្សែភាពយន្តដោយលោក *ម៉ាកសែល កាមីស៍* ក្នុងអំឡុងឆ្នាំ១៩៦១ ឬ ១៩៦២។ នៅឆ្នាំ១៩៦៣ ភាពយន្តនេះបាននាំទៅបញ្ចាំងនៅប្រទេសបារាំង។ នៅឆ្នាំ១៩៦៤ បញ្ចាំងនៅប្រទេសសិង្ហបុរី ក្នុងពិធីសម្ពោធមហោស្រពសិល្បៈសាកល ដោយបានទទួលជោគជ័យ និងមានការគាំទ្រ និងកោតសរសើរពីសំណាក់ទស្សនិកជនយ៉ាងខ្លាំង។

«អប្សរា» ក៏បានលេចរូបរាងតាមវិចិត្រកម្មគំនូរដោយវិចិត្រករខ្មែរក្នុងប្រវត្តិវិចិត្រករខ្មែរ នាទសវត្សរ៍ឆ្នាំ១៩៦០-១៩៧០។ វិចិត្រករដ៏ល្បីល្បាញ និងជាមិត្តជិតស្និទ្ធរបស់អធិរាជសម្លេងមាស *ស៊ីន ស៊ីសាមុត* ឈ្មោះ *ញ៉ឹក នឹម* (១៩៣៤-១៩៧៨)។ លោក *ញ៉ឹក នឹម* ជាអ្នកមានទេពកោសល្យ ព្រមទាំងបានសិក្សាមុខវិជ្ជាគំនូរនៅឯសាលាវិចិត្រសិល្បៈខេមរៈ (បច្ចុប្បន្នជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ) បានក្លាយជាវិចិត្រករដ៏ល្បីល្បាញដោយបានបង្កើតស្នាដៃជាច្រើនទាំងក្នុងប្រទេសទាំងលើឆាកអន្តរជាតិ។



*រូបគំនូរអប្សរាស្នាដៃវិចិត្រករ ញ៉ឹក នឹម*

របាំអប្សរាខ្មែរ ក៏មានជនបរទេសហាត់រាំ។



*នាដការីអបអរជនជាតិចិន*

រីឯនាដការីដែលបានសម្ដែងក្នុងក្របខណ្ឌជាតិមានដូចជា ៖

អ្នកស្រី សេង ស្រីមុំ អ្នកស្រី វ៉ែន សាវ៉ៃ

អ្នកស្រី ឌុក ថាច អ្នកស្រី វ៉ែន សាវង្ស

អ្នកស្រី ឃឹម ទេវី អ្នកស្រី ម៉ម កណិការ

អ្នកស្រី អ៊ុក ផល្លា កញ្ញា សុខ សុខឿន។

 

## សេចក្ដីសន្និដ្ឋាន

អត្ថាធិប្បាយកន្លងមកបានបង្ហាញថា របាំអប្សរា គឺជាមោទនភាពជាតិខ្មែរ។ ការចារឹកនាមរបាំព្រះរាជទ្រព្យ ដែលក្នុងនោះមានរបាំតន្ដ្រីអប្សរា ដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនាឆ្នាំ២០០៣ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បានបញ្ជាក់ពីតម្លៃសាកលដ៏ធំធេងអស្ចារ្យនៃស្នាដៃសិល្បៈទស្សនីយភាពខ្មែរ និងការរួមទទួលខុសត្រូវក្នុងការការពារថែរក្សាពីសំណាក់អន្តរជាតិ។ ប៉ុន្ដែ ដោយឡែកចំពោះប្រជាជាតិខ្មែរ គ្រាន់តែការរកឃើញខាងលើថា របាំអប្សរា កើតឡើងពីបញ្ញាញាណដ៏ជ្រៅជ្រះរបស់ប្រជាជាតិខ្មែរនោះ អាចមានន័យថា របាំអប្សរា ស្ថិតនៅយ៉ាងជ្រាលជ្រៅក្នុងជម្រៅបេះដូងខ្មែរគ្រប់ៗរូប លើសជាតិសាសន៍ណាទាំងអស់ ឯការទទួលខុសត្រូវ ក៏ត្រូវតែជាបន្ទុករបស់ប្រជាជនខ្មែរធ្ងន់ជាងគេ ខ្មែរគ្រប់រូបត្រូវតែយល់ដឹងបញ្ហានេះដោយមិនត្រូវពឹងផ្អែកទាំងស្រុងលើអន្តរជាតិទេ៕